

មន្ទីរកសិកម្មខេត្តកណ្តាល

# ស្វាយកែវល្មៀត











ឆ្នាំ២០១៤

# សៀវភៅបច្ចេកទេសដាំដំណាំ
# ស្វាយកែវល្មៀត

រៀបចំដោយមន្ទីរកសិកម្មខេត្តកណ្តាល

អ្នករៀបរៀង

លោក អ៊ិន ចាន់យ៉ារិទ្ធ

អ្នកផ្តល់យោបល់ និង កែសម្រួល

លោក ប៊ុនទួន ស៊ីមូណា

លោក លីម ងួនគ្រុយ

លោក ហ៊ី សុផល

លោក ឡុង រ៉ា

លោក ផា ចាម

លោក ប៉ាន់ ខេមរិន្ទ

លោក ហាស់ វុទ្ធី

លោក អាង វណ្ណា

AIDOC
Code: 118-009
Date:
Donated by:

# សេចក្តីផ្តើម

ដំណាំស្វាយគឺជាប្រភេទដំណាំ ដែលមានអាយុកាលវែងជាងដំណាំឈើហូបផ្លែដ៏ទៃទៀត ហើយវាផ្តល់ផលមួយដងក្នុងមួយឆ្នាំទៅតាមរដូវកាលរបស់វា។ ដំណាំស្វាយគឺជាប្រភេទដំណាំ ដែលមានសារៈសំខាន់ចំពោះមនុស្ស និង សត្វ ។ វាផ្តល់នូវជីវជាតិផ្សេងៗដូចជា សារធាតុខនិជ សារធាតុសរីរាង្គ ដែលជាសារធាតុចាំបាច់សម្រាប់មនុស្សក្នុងការបណ្តុររូបធាតុ ។ ក្រៅពីនេះផ្លែស្វាយអាចផ្តល់នូវប្រភេទស្ករមួយចំនួនដូចជាគ្លុយកូស សាក់ការ៉ូស និង វីតាមីនA, B, B6, C, PP.. ថែមទាំងមានគុណប្រយោជន៍ដល់សុខភាពរបស់មនុស្សផងដែរដូចជាៈ

**-ទប់ស្កាត់រោគមហារីកៈ** ការស្រាវជ្រាវបានបង្ហាញថា សារធាតុផ្សំនៅក្នុងផ្លែស្វាយ អាចទប់ស្កាត់នឹងរោគមហារីកផ្សេងៗដូចជាមហារីកសុដន់ និងមហារីកក្រពេញប្រូស្តាតជាដើម។

**-កាត់បន្ថយជាតិកូឡេស្តេរ៉ូលៈ** ដោយសារតែស្វាយមានជាតិកាកសរសៃខ្ពស់ និងវីតាមីនC ដែលអាចជួយកាត់បន្ថយកម្រិតកូឡេស្តេរ៉ូលឱ្យកាន់តែទាប។

**-សម្អាតស្បែកៈ** ស្វាយក៏ត្រូវបានប្រើសម្រាប់ជំនួយដល់ស្បែកទាំងខាងក្នុង និងខាងក្រៅ ។ គេអាចយកស្វាយទុំទៅបិទ

បំពោកនៅលើមុខ កម្មេចស្វាយនឹងជួយលាងសម្អាតមុន ដែលមាននៅលើមុខបានយ៉ាងស្អាត និង ភ្លឺរលោង។

**-ជំនួយសុខភាពភ្នែក៖** បើលោកអ្នកទទួលទានផ្លែស្វាយប្រហែលជា២៥% នៃតម្រូវការវីតាមីនA ប្រចាំថ្ងៃ នោះលោកអ្នកនឹងទទួលបាននូវសុខភាពភ្នែកល្អ និងអាចកាត់បន្ថយភាពងងឹតនៅពេលយប់ ក៏ដូចជាភាពស្ងួតភ្នែកជាដើម។

**-រក្សាកម្រិតជាតិប្រៃក្នុងខ្លួនឱ្យស្ថិតស្ថេរ៖** ជាតិអាស៊ីតផ្សេងៗដែលមាននៅក្នុងផ្លែស្វាយអាចជួយរក្សាលំនឹងនៃកម្រិតជាតិប្រៃក្នុងខ្លួនរបស់យើងបាន។

**-ជំនួយក្នុងការរក្សាកម្រិតជាតិស្ករ៖** ផ្លែស្វាយមានកម្រិតជាតិស្ករក្នុងឈាមទាបបំផុត ដែលមិនប៉ះពាល់កម្រិតជាតិស្ករក្នុងឈាមរបស់លោកអ្នកឡើយ។

**-បង្កើនសមត្ថភាពផ្លូវភេទ៖** ផ្លែស្វាយមានជាតិវីតាមីនE ខ្ពស់ ។ ទំនាក់ទំនងរវាងចំណង់ផ្លូវភេទ និងវីតាមីនE ពិតជាទាក់ទងគ្នាយ៉ាងពិតប្រាកដ ហើយផ្លែស្វាយក៏ជាគ្រឿងជំនួយមួយដែរ។

**-បង្កើនសមត្ថភាពប្រព័ន្ធបញ្ចេញចោល៖** ផ្លែល្ហុងជាផ្លែឈើដែលអាចជួយសម្រួលដល់ប្រព័ន្ធបញ្ចេញចោលបាន តែផ្លែស្វាយក៏មានសារប្រយោជន៍ដ៏វិសេសវិសាលដែរ ក្នុងការ

សម្រួលដល់ការរំលាយអាហារ និងការបញ្ចេញ ចោលមិនចាញ់ផ្លែល្ហុងឡើយ។

**-កាត់បន្ថយកម្តៅក្នុងខ្លួន៖** ទឹកផ្លែស្វាយបៃតងលាយជាមួយទឹក និងជាតិស្ករតិចៗអាចជួយបន្ថយកម្តៅក្នុងខ្លួនបាន។

**-បង្កើនសមត្ថភាពប្រព័ន្ធការពាររាងកាយ៖** បរិមាណចំនួនវីតាមីនC និង A នៅក្នុងផ្លែស្វាយ និងសារធាតុផ្សេងៗទៀតអាចជួយឱ្យប្រព័ន្ធការពាររាងកាយមានសុខភាពល្អ និងមាំមួន ។

ដំណាំស្វាយដែលមានដាំច្រើនជាងគេ នៅក្នុងប្រទេសកម្ពុជាយើងជាពិសេសនៅក្នុងខេត្តកណ្តាល, ខេត្តកំពង់ស្ពឺ...... ប៉ុន្តែយើងនៅមិនទាន់មានពូជ ស្វាយពិតប្រាកដណាមួយ ដែលអាចនាំចេញយកទៅលក់នៅក្រៅប្រទេសបាននៅឡើយទេ គឺមានត្រឹមតែស្វាយប្រភេទបែបធម្មតា ជាពូជក្នុងស្រុកដែលបានដាំតៗគ្នាជារហូតមក ។ ទោះបីជាយ៉ាងណាក៏ដោយស្វាយដែលទទួលបាន គឺល្មមគ្រប់គ្រាន់សម្រាប់បំពេញសេចក្តីត្រូវការនៅក្នុងស្រុកតែប៉ុណ្ណោះ ។ តែសម្រាប់ប្រទេសដទៃដូចជាតៃវ៉ាន់ ហ្វីលីពីន ថៃ ម៉ិចស៊ីកូវិញ គេមានពូជស្វាយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ អាចនាំចេញយកទៅលក់នៅក្រៅប្រទេសបានប្រាក់កម្រៃច្រើនជាងការលក់នៅក្នុងស្រុក។ ក្នុងចំណោមពូជស្វាយទាំងអស់ ដែលចរាចរនៅលើទីផ្សារអន្តរជាតិមានតែពូជស្វាយតៃវ៉ាន់ឈ្មោះថា "IRWIN" មួយប៉ុណ្ណោះត្រូវបានក្រុម

ជនអ្នកទេសចរណ៍សរសើរថា មានរសជាតិ និង គុណភាពល្អជាងស្វាយណាៗទាំងអស់ បន្ទាប់មកគឺស្វាយឈ្មោះ "Carabao" មកពីប្រទេសហ្វីលីពីន ត្រូវបានគេចាត់ទុកថាជាស្វាយពូជល្អបំផុតផងដែរ ។ ដោយឡែកនាពេលបច្ចុប្បន្ននេះនៅប្រទេសកម្ពុជាយើងពូជស្វាយកែវចិន និងពូជស្វាយក្នុងស្រុកមួយចំនួនទៀតពុំមានអ្នកចាប់អារម្មណ៍ដាំដុះឡើងវិញឡើយ។ គេនិយមដាំតែស្វាយកែវល្មៀត ដោយប្រភេទស្វាយនេះមានទីផ្សារក្នុងប្រទេស និងក្រៅប្រទេស។



**ស្វាយកែវល្មៀត**

# ដំណាំស្វាយកែវល្មៀត

## ១-ពូជ និង ការជ្រើសពូជ

ពូជគឺជាកត្តាសំខាន់ណាស់ ក្នុងការកំណត់ទិន្នផល ដូច្នេះមុននឹងធ្វើការដាំដុះ ត្រូវជ្រើសរើសយកពូជណាដែលឲ្យផលច្រើន និងផ្លែណាដែលមានទំហំធំដូចមេបា គ្មានជម្ងឺ គ្មានសត្វល្អិត ធន់ជម្ងឺ ការបណ្តុះដោយគ្រាប់គឺមិនសូវសុទ្ធល្អដូចការសាកមែក, ការភ្ជាប់ភ្នែក និងតមែកនោះទេ ។

### ក.ការបន្តពូជដោយគ្រាប់:

គឺជាការយកគ្រាប់រុក្ខជាតិមកបណ្តុះ នៅទីកន្លែងមួយដែលបានរៀបចំទុកសម្រាប់បណ្តុះ។









## ខ.ការបន្តពូជដោយសាក:

ការសាកមែក គឺជាការបំបែករុក្ខជាតិដោយប្រើវិធីមួយ ដែលធ្វើឲ្យមែករុក្ខជាតិកើតឫសក្នុងខណៈដែលនៅជាប់នឹងដើមមេ ពេលមែកចេញឫសល្អហើយក៏កាត់ទៅផ្សាំមុនដាំ ឬយកទៅដាំតែម្ដងក៏បាន។



ជំហានទី១



ជំហានទី២



ជំហានទី៣



ជំហានទី៤

<u>ជំហានទី១</u> ចៀរសំបករួចយកសរសៃចេញ។

<u>ជំហានទី២</u> យកដីមមោកមកហ៊ុមជុំវិញ(បើមានអ័រកម៉ូនប្រើជាជំនួយ)

<u>ជំហានទី៣</u> យកស្រកីដូងត្រាំទឹក២-៣ថ្ងៃមកហ៊ុមជុំវិញ។

<u>ជំហានទី៤</u> យកប្លាស្ទីកមកហ៊ុមជុំវិញ។

## គ.ការបន្តពូជដោយការភ្ជាប់ភ្នែក:

ការភ្ជាប់ភ្នែកគឺជាវិធីបំបែកពូជរុក្ខជាតិមួយផ្នែកទៀត ជាវិធីដែលនាំយកផែនភ្នែកពីមែកពូជល្អ ទៅភ្ជាប់ជាមួយដើមទម្រ ដើម្បីឲ្យបានពូជតាមតម្រូវការ។



ជំហានទី១



ជំហានទី២

**ជំហានទី១** ឆូតដើមជារូបអក្សរតេTរួចហើយប្រើកាំបិតមួយផ្សេងទៀតដើម្បីបើកសំបកចេញ។

**ជំហានទី២** ជ្រើសរើសយកភ្នែក ដែលកំពុងរីកលូតលាស់ពីមែកពូជល្អ ចៀរយកភ្នែកឲ្យជាប់សាច់ឈើមកផង តែយកសាច់ឈើចេញមុននឹងដាក់សៀតចូលក្នុងដើមទម្រ។


ជំហានទី៣


ជំហានទី៤

<u>**ជំហានទី៣**</u> យកផ្នែករបស់ភ្នែកដែលបានឆ្កឹះទុក យកសាច់ឈើចេញហើយយកទៅស៊កចូលនៅក្នុងកន្លែងដែលបើកសំបកទុកនៅដើមទម្រ។

<u>**ជំហានទី៤**</u> ពេលស៊កចូលរួចរាល់ហើយរុំដោយប្លាស្ទីកថ្លា ដើម្បីការពារទឹកចូល ទុកចោលរយៈពេលប្រមាណ១៥ទៅ២០ថ្ងៃ ភ្នែកនឹងភ្ជាប់ជាមួយដើម ទើបបើកប្លាស្ទីកដែលរុំនោះចេញ។

**ឃ.ការបន្តពូជដោយការតមែក:**

ការតមែកគឺជាការបំបែកពូជដោយនាំយកមែកពូជដែល

មានភ្នែកច្រើនជាងមួយទៅធ្វើការតភ្ជាប់មែកលើដើមទម្រ ដើម្បីឲ្យបានពូជល្អតាមតម្រូវការ មែកពូជ និង ដើមទម្រនឹងភ្ជាប់គ្នាជារុក្ខជាតិតែមួយ។


ជំហានទី១


ជំហានទី២

**ជំហានទី១** ជ្រើសរើសមែកដើមទម្រ ហើយប្រើកាំបិតដែលមុត ចិតដើមទម្រដូចក្នុងរូប ឲ្យបានប្រវែងប្រមាណ២ធ្នាប់ ដើម្បីត្រៀមយកត្រួយមកតភ្ជាប់។

**ជំហានទី២** ត្រៀមត្រួយនៃមែកពូជល្អ ដោយកាត់ស្លឹកចេញ ប្រើកាំបិតមុតចិតមែកឲ្យបញ្ជិតចុះ ឲ្យផ្នែកដែលភ្ជាប់ជាមួយដើមទម្រល្អនឹងសមល្មមជាមួយស្នាមចិតនៅជំហានទី១។



ជំហានទី៣



ជំហានទី៤

**ជំហានទី៣** យកត្រួយពូជល្អមកស៊កក្នុងដើម ដែលត្រៀមរួចជាស្រេច រយៈពេលដែលប្រតិបត្តតាមជំហានផ្សេងៗនេះគួរជៀសវាងពីការទង្គិច ឬ កកិតធ្វើឲ្យខូចមុខកាត់ និងការរលាត់ដែលបណ្ដាលមកពីកាំបិតមុតពេកអាចធ្វើឲ្យមិនជាប់។

**ជំហានទី៤** ក្រោយពីយកត្រួយមកស៊កហើយប្រើប្លាស្ទីករុំឲ្យណែន លក្ខណៈនៃការរុំនោះគឺរុំពីក្រោមឡើងលើដើម្បីការពារកុំទឹកជ្រាបចូលបាន។

ដំណាំស្វាយកែវល្មៀត អាចឲ្យផលចាប់ពីអាយុ៣ឆ្នាំឡើងទៅបើដាំដោយគ្រាប់។

## ២-ការបណ្តុះកូន

### ក-ការជ្រើសរើសទីតាំងថ្នាលបណ្តុះ

ទីតាំង និង ការរៀបចំថ្នាលជាកត្តាមួយដ៏សំខាន់សម្រាប់ធ្វើឲ្យការដុះពន្លកនៃកូនដំណាំបានគង់វង់ ក្នុងបរិមាណខ្ពស់និងមានសុខភាពល្អនោះគឺនៅជិតប្រភពទឹក, ដីទួល, មានពន្លឺ គ្រប់គ្រាន់និងជាកន្លែងដែលងាយស្រួលក្នុងការការពារ។



### ខ-ការរៀបចំថ្នាលបណ្តុះ

ត្រូវលើកថ្នាលឲ្យបានកម្ពស់២តឹក ទទឹង១ម៉ែត្រ និងបណ្តោយអាស្រ័យទៅតាមប្រវែងជាក់ស្តែង ដែលយើងចង់បាន ។ កាប់ដីឲ្យម៉ត់ និងហាលដីក្នុងរយៈពេលពី២ ទៅ ៣ សប្តាហ៍ដើម្បីសម្លាប់បាក់តេរី, សត្វល្អិតចង្រៃ, ជម្ងឺផ្សេងៗនិងជ្រោយដីរួចរើសយកស្មៅចេញ។



## គ-ការបណ្តុះកូនស្វាយ

ត្រូវបកសំបកគ្រាប់ស្វាយ ដែលជ្រើសរើសរួចក្រោយពីហួបរយៈពេល២ទៅ៣ថ្ងៃ យកគ្រាប់កប់ក្នុងរងដែលបានរៀបចំហើយ ចម្ងាយប្រហែល២តឹកពីគ្រាប់មួយទៅគ្រាប់មួយ លប់ដីម៉ត់ពីលើគ្រាប់ស្វាយឲ្យបានជិតល្អ ដោយគ្របចំបើងពីលើស្រោចទឹកឲ្យសើមជាប្រចាំ។





### ឃ-ការផ្សាំកូនស្វាយក្នុងថង់

រយៈពេលមួយខែក្រោយបន្ទាប់ពីការបណ្តុះក្នុងថ្នាលមក យើងអាចយកកូនស្វាយទៅផ្សាំក្នុងថង់ ត្រូវច្រកដោយប្រើដីកំប៉ុស្តិ៍មួយភាគ ផេះអង្កាមមួយភាគ និងដីខ្សាច់មួយភាគ កូនស្វាយដែលដុះលើសពីមួយដើមអាចបំបែកចេញបាន រួចដាក់ក្នុងថង់ផ្សេងទៀត។



## ៣-បច្ចេកទេសដាំដុះ

### ក-ការជ្រើសរើសកន្លែងដាំដុះ

ដំណាំស្វាយដុះលូតលាស់ល្អ លើប្រភេទដីមានជីជាតិល្អPhចាប់ពី ៥,៥-៧,៥ សីតុណ្ហភាពសមស្រប២៧ ទៅ ៣០

អង្សាសេ, កំពស់ទឹកភ្លៀងប្រចាំឆ្នាំ ៧៥០ ទៅ ២២៥០ ម.ល និងសំណើមបរិយាកាស៧០ទៅ៨០ភាគរយនៅជិតប្រភពទឹក និងឆ្ងាយពីដើមឈើធំៗ។



## ខ-ការជីករណ្ដៅ

រណ្ដៅដាំស្វាយត្រូវមានទំហំសមល្មម គឺជម្រៅមួយម៉ែត្រ ទទឹងមួយម៉ែត្រនិងបណ្ដោយមួយម៉ែត្រ គំលាតពីរណ្ដៅមួយទៅរណ្ដៅមួយមានចម្ងាយ ៦ម៉ែត្រx៦ម៉ែត្រ មានន័យថា ចន្លោះពីរណ្ដៅមួយទៅរណ្ដៅមួយប្រវែង៦ម៉ែត្រ និងពីជួរមួយទៅជួរមួយទៀត៦ម៉ែត្រ ហើយធ្វើយ៉ាងណាកំណត់ជួរឲ្យប៉ះនឹងពន្លឺថ្ងៃស្មើៗគ្នា។

# ការជីករណ្ដៅត្រៀមសម្រាប់ដាំស្វាយ



## គ-ការដាក់ជីក្នុងរណ្តៅ

ក្រោយពេលជីករណ្តៅរួច មុនដាំត្រូវប្រមូលកំទេចកំទីសំរាម, ដីដំបូក, ដីមានជីជាតិ, ផេះ, លាមកសត្វ ឬជីកំប៉ុស្ដិ៍ដាក់ក្នុងរណ្តៅឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដាក់ជីស៊ុពែផូស្វាត៥០០-១០០០ក្រាម, ជីផូស្វ័រ២០០ក្រាម ឬ ជីNPK ១៦-១៦-៨ ចំនួន២០០-៣០០ក្រាម លាយជាមួយថ្នាំកសិកម្ម DIAZINON១០ក្រាម ក្នុងមួយរណ្តៅ ហើយរក្សាទុកក្នុងរយៈពេលមួយដើម្បីឲ្យកាកសំណល់សរីរាង្គពុកផុយរលួយ (១៥ថ្ងៃទៅ៣០ថ្ងៃ ពិសេសនៅពេលលូកដៃចូលក្នុងរណ្តៅបាត់កំដៅគឺត្រជាក់ទើបអាចដាំបាន)។

## ឃ-ការដាំកូនស្វាយ

ត្រូវពិនិត្យ និង អនុវត្តន៍ឲ្យបានហ្មត់ចត់ ដូចជាកូនស្វាយត្រូវមានអាយុយ៉ាងតិច២ខែ ។ មុនដាំត្រូវចៀរថង់ថ្នមៗ ដោយកាំបិតមុតការពារកុំឲ្យបែកដី ដាំនៅពេលល្ងាចសង្កត់ដីឲ្យណែន ដើម្បីឲ្យវាទទួលសំណើមនៅពេលយប់ និងស្រោចទឹកដើម្បីឲ្យឫសឆាប់ចាប់នឹងដីថ្មី ។ ស្វាយអាចដាំដោយគ្រាប់ផ្ទាល់បាន។



## ៤-ការថែទាំ

### ក-ការដាក់ជីបំប៉ន

ជីបំប៉នត្រូវដាក់ពី២ ទៅ ៤ដងក្នុងមួយឆ្នាំ ឬ នៅរៀងរាល់ដើម និងចុងរដូវវស្សា ដោយជីករណ្ដៅព័ទ្ធជុំវិញ (ចម្ងាយពីគល់ស្វាយទៅចុងមែកស្វាយដែលបែកចេញទៅខាងវែងជាងគេ) ជម្រៅកន្លះម៉ែត្រ ទំហំពី ២ទៅ ៤តឹក ។ ការដាក់ជីបំប៉នជាការចាំបាច់មួយដើម្បីឲ្យដំណាំស្វាយដុះលូតលាស់ ដើមរឹងមាំល្អ ឈ្មុះជម្ងឺ និងសត្វល្អិត ប៉ុន្តែទាល់តែយើងដាក់ជីតាមតម្រូវការរបស់ដំណាំស្វាយ មិនចេះតែដាក់តាមការនឹកឃើញនោះទេ ពិសេសត្រូវដាក់ជីធម្មជាតិផងដែរដើម្បីរក្សាជីជាតិដី។

ដើមស្វាយនៅតូច ក្រោយដាំបាន២ឆ្នាំ រយៈពេល៣ខែត្រូវដាក់ជីម្ដងដាក់មុនឬក្រោយរដូវភ្លៀងមួយឆ្នាំដាក់ជីប្រហែលពី៣០០-៥០០ក្រាម ជីNPK១៦-១៦-៨ និងដាក់ជីអ៊ុយរ៉េចំនួន៣០០ក្រាមក្នុងមួយដើម ។ ឆ្នាំទី៣ដាក់ជីចំនួន២០០-២៥០ក្រាម ជីNPK១៦-១៦-៨ ដោយដាក់លាយជាមួយជីធម្មជាតិជប៉ុនសញ្ញាផែនដី០.៥-១គ.ក្រក្នុងមួយដើម។ ពេលចេញផ្កាដំបូងត្រូវកាត់ចោលទុកដល់ឆ្នាំបន្ទាប់ទើបយក ដើម្បីឲ្យដើមស្វាយលូតលាស់ល្អ ដាក់ជី០.៥គ.ក្រជី NPK១៦-១៦-៨ ក្នុងមួយដើមដាក់បួនដងក្នុងមួយឆ្នាំ។


ទីតាំងដាក់ជីបំប៉ន


NPK ២០-២០-១៥ Hi-End
NPK ២០-២០-១៥
NPK ១៦-២០-០

តារាងដាក់ជីបំប៉នប្រើប្រាស់ជី

| អាយុ | ជីធម្មជាតិ ជប៉ុនសញ្ញាផែនដី | បរិមាណជីប្រើក្នុង១ដើម/១ឆ្នាំគិតជាក្រាម | | |
|---|---|---|---|---|
| | | អាសូត(N) | ផូស្វ័រ(P) | ប៉ូតាស្យូម (K) |
| ១ឆ្នាំ | ០.៥-១ គ.ក្រ | ១០០ | ៥០ | ១០០ |
| ២ឆ្នាំ | ០.៥-១ គ.ក្រ | ២០០ | ១០០ | ២០០ |
| ៣ឆ្នាំ | ០.៥-១ គ.ក្រ | ៣០០ | ២០០ | ៣០០ |
| ៤ឆ្នាំ | ១-៣ គ.ក្រ | ៤០០ | ៣០០ | ៤០០ |
| ៥ឆ្នាំ | ១-៣ គ.ក្រ | ៥០០ | ៤០០ | ៥០០ |
| ៦ឆ្នាំ | ១-៣ គ.ក្រ | ៦០០ | ៥០០ | ៦០០ |

## ខ-ការស្រោចទឹក

ការស្រោចទឹកគឺធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់រោមជញ្ជក់របស់ឫសស្រូបយកសារធាតុចិញ្ចឹម។ ស្រោចទឹកបំប៉នឲ្យបានទៀងទាត់ពេលកូនស្វាយនៅតូច ស្រោចទឹកពេលណាដែលយើងសង្កេតឃើញថា ដំណាំស្វាយខ្វះជាតិទឹក។ នៅពេលវាពេញវ័យស្រោចទឹកបំប៉នឲ្យបានច្រើនជាប្រចាំនៅមុន និងក្នុងពេលដំណាំស្វាយចេញផ្កា។

## គ-ការកាត់តែងមែក

ការកាត់តែងមែក គឺត្រូវធ្វើឡើងរៀងរាល់ឆ្នាំគឺក្រោយពេលប្រមូលផលរួច ហើយមែកដែលត្រូវកាត់ចោលនោះមានដូចជា:

-មែកចាស់ពេកគ្មានផ្លែ មែកសំយ៉ុងចុះ
-មែកដុះចាក់ទៅក្នុងមិនត្រូវពន្លឺ
-មែកដែលងាប់
-មែកដែលបាក់
-មែកជិតគ្នា
-មែកអំពង់(មែកស៊ីជីខ្លាំង)
-មែកដែលដុះចេញពីឫស
-មែកមានជម្ងឺ និងសត្វល្អិតបំផ្លាញ
-មែកដែលមានដុះរុក្ខជាតិបញ្ញើរក្អែក




B. Cutting a small branch
C. Cutting a larger branch

ការធ្វើរបៀបនេះ ដើម្បីឲ្យសុខភាពមែកល្អ ទទួលពន្លឺបានគ្រប់គ្រាន់មានខ្យល់ចេញចូលល្អនឹងទទួលបានស្វាយមានផ្លែធំ។



## ៥-ការការពារសត្វល្អិតចង្រៃ និង ជម្ងឺ

យើងមានវិធីសាស្ត្រច្រើនយ៉ាងដូច ជាដាក់កំបោរស សាច់ជូរខៀវ ស្ពាន់ធ័រ ជុំវិញគល់ ការពារសត្វកណ្ដៀរ ប្រើថ្នាំពុលផ្សំពីធម្មជាតិ នៅពេលសត្វល្អិតបំផ្លាញផ្កាឬក្ដឹប(រាល់ពេលប្រើថ្នាំពុល ត្រូវដាក់ស្លាកសញ្ញាសំគាល់ជៀសវាងមានគ្រោះថ្នាក់ដល់មនុស្ស និង សត្វ)។ មែកដែលមានជម្ងឺត្រូវកាប់រួចយកទៅកប់ឬដុតចោល និងបំពក់ភ្លើងដើម្បីឲ្យផ្សែងបណ្ដេញសត្វល្អិតចង្រៃ។

### ក.សត្វល្អិតចង្រៃលើដំណាំស្វាយ:

-ដង្កូវស៊ីរូងដើមស្វាយ: នៅក្នុងរយៈពេលបួនប្រាំឆ្នាំកន្លងទៅ និងរហូតមកទល់ពេលនេះ ការខូចខាតទៅលើដំណាំស្វាយដោយសារដង្កូវស៊ីរូងដើមមានចំនួនកើនឡើង និងរីករាលដាលពីតំបន់មួយទៅតំបន់មួយទៀត ដោយគ្មានវិធីណាអាចទប់ស្កាត់វាបានឡើយ។ ចំការស្វាយមួយចំនួនត្រូវបានបំផ្លាញស្ទើរទាំងស្រុងដោយបញ្ហានេះ ព្រោះមិនដឹងថាត្រូវកំចាត់វាដោយវិធីណា។ តាមការពិតទៅដង្កូវស៊ីរូងចូលក្នុងមែកស្វាយនេះ វាកើតឡើងដោយសារសត្វ មួយប្រភេទមានឈ្មោះវិទ្យាសាស្ត្រថា "Batocera rufomaculata"






ជាដំបូងសត្វញី វាហើរមកទុំលើមែកស្វាយខ្ពស់ខាងលើៗ ឬគល់ស្វាយ ដែលមានកម្ពស់ប្រហែល៧០សង្ទីម៉ែត្រ ពីដី បន្ទាប់មកវាស៊ីចោះប្រហោងលើសំបកមែកស្វាយ បន្ទាប់មកទៀតវាពងដាក់ក្រោមស្រទាប់សំបកមែកស្វាយ។ បន្ទាប់ពីពងវាញាស់វាក៏ក្លាយជាកូនដង្កូវមានពណ៌ស ដង្កូវនេះវាចាប់ផ្ដើមស៊ីលុងពីសាច់សំបកក្រៅក្រោមស្រទាប់សំបកស្វាយ បន្តមកវាស៊ីចោះចូលទៅក្នុងបណ្ដូលខ្ពស់ក្នុងមែកស្វាយ រួចបន្តស៊ីចុះទៅគល់មែកស្វាយ។ នៅខណៈពេលវាស៊ីចោះតាមបណ្ដូលក្នុងរបស់មែកស្វាយ វាបានចោះជាប្រហោងច្រើនកន្លែង ដើម្បីបញ្ចេញកំទេចឈើដែលវាបានស៊ី ដើម្បីច្រាលកំទេចនោះចេញមកក្រៅ និងជាការបើកផ្លូវឲ្យវាស៊ីទៅមុខទៀត។ ដង្កូវ

នេះរីកធំធាត់ម្ដងបន្តិចៗរហូតមានទំហំខ្លួនប៉ុនធូប ឬ ប៉ុនចុងចង្កឹះ ក្នុងទំហំនេះវាមានសមត្ថភាពអាចខាំស៊ីសាច់ខាងក្នុងរបស់មែកស្វាយ រហូតកើតបានជារង្វង់មួយធំក្រឡឹងជុំវិញមែកស្វាយ តែស្ថិតក្រោមសំបកខាងក្រៅ ជាហេតុធ្វើឲ្យមែកស្វាយនោះងាប់បាក់មែកមានធំមានតូច ទៅតាមអ្វីដែលវាបានខាំចោះស៊ីមែកស្វាយមួយទំហំប៉ុនកជើងឬប៉ុនកំភួនដៃ។ វាប្រើពេលចោះស៊ីត្រឹមតែជាង២០ម៉ោងតែប៉ុណ្ណោះ ជួនកាលអាចប្រើពេលរហូតពីរទៅបីថ្ងៃក៏មានដែរ ។ សកម្មភាពស៊ីបំផ្លាញរបស់ដង្កូវនេះកើតឡើងភាគច្រើននៅពេលយប់។ សត្វនេះវាចូលចិត្តយកដើមស្វាយចន្ទី ដើមស្វាយ និងដើមខ្នុរធ្វើជាកន្លែងឲ្យវាពងដាក់ វាកម្រប្រើប្រាស់ដើមឈើព្រៃសម្រាប់ពងណាស់ យើងក៏មិនបានដឹងថាមកពីមូលហេតុអ្វីដែរ។

➤**វិធីកំចាត់:** ដើម្បីកាត់បន្ថយការបំផ្លាញដោយសារសត្វនេះ យើងត្រូវកំចាត់សត្វនេះជាមុនសិន ដោយប្រើវិធីដូចខាងក្រោម : ធ្វើឈើទំពក់មួយពីឫស្សីពីងពង់ ពត់ដែកសរសៃទំហំ១២លីឲ្យក្រងុក ចាប់ភ្ជាប់នៅចុងទំពក់ឲ្យមាំទុកសម្រាប់ការមែកស្វាយដែលបាក់ចេញ និងសម្រាប់អង្រួនមែកស្វាយ។ ប្រើពិលពាក់លើក្បាល សម្រាប់ឆ្លុះរួមជាមួយធុងមួយសម្រាប់ដាក់សត្វនេះ។



យើងអាចឆ្លុះរកមើលសត្វនេះ ចាប់ពីពេលថ្ងៃលិច ប្រហែលម៉ោង ៧ ទៅ ម៉ោង ៨ នៅតាមដើមស្វាយក្នុងចំការ បើឃើញវាទុំលើមែកណាមួយសូមប្រើទំពក់ចាប់ការអង្រន់មែកនោះឲ្យធ្លាក់វាចុះមករួចរើសដាក់ធុង ត្រូវធ្វើបែបនេះតាមដើមស្វាយនីមួយៗ។ តែជួនកាលយើងមើលវាអត់ឃើញទេ តែត្រូវប្រើទំពក់អង្រួនមែកណាដែលនៅលើគេ ដើម្បីឲ្យវាហើរចេញ ឬឲ្យវាជ្រុះមកដី។ ព្យាយាមធ្វើបែបនេះឲ្យបានរាល់យប់ជាប់គ្នា ដើម្បីកាត់បន្ថយចំនួនរបស់វាឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ វិធីមួយទៀតនោះ គឺចាប់អំពូលអាគុយដើម្បីទាក់ទាញវាឲ្យចេញមករកពន្លឺភ្លើងរួចចាប់វា។ សម្រាប់មែកស្វាយដែលត្រូវដង្កូវចោះស៊ីរួចហើយនោះ សូមប្រើរណាផ្ទដើម្បីកាត់

មែកស្វាយនោះចោល រួចលាបកំបោរសត្រង់មុខដែលបានកាត់ ។ លះស្លឹកនិងមែកស្វាយចោលឲ្យបានច្រើន ដើម្បីកុំឲ្យសត្វរៃវាមកទុំ ព្រោះសត្វនេះចូលចិត្តទីងងឹតនៅក្នុងដើមដែលមានមែកស៊ុបទ្រុបច្រើន។

ប្រើថ្នាំកសិកម្មប្រភេទ Carbosulfan, Carbaryl, Thiamethoxam, Acetamiprid, Imidacloprid សម្រាប់លាបលើមែកស្វាយឲ្យបានប្រវែង ១ម៉ែត្រពីគល់មែក បាញ់លើដើមស្វាយឬបាញ់ចូលរន្ធរួចបិទដី។ វិធីមួយទៀតនោះគឺបាញ់ការសសម្រាប់បិទឈើ (មានលក់នៅផ្សារទួលទំពូង) ចូលតាមរន្ធដែលវាបានចោះ បន្ទាប់មកប្រើមែកឈើសម្រាប់ញាត់ភ្ជិតរន្ធនោះ។ ព្យាយាមធ្វើបែបនេះឲ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការខូចខាតលើដំណាំស្វាយ។

-<u>មមាចផ្កាស្វាយៈ</u>





មមាចផ្កាស្វាយមានវត្តមាននៅពេលស្វាយផ្កា វាមកជញ្ជក់ទងផ្កាយករុក្ខរស់ ធ្វើឲ្យហៀរជ័របណ្ដាលឲ្យផ្ការុះរោយមិនកាន់ក្ដិប។ ប្រសិនបើការបំផ្លាញខ្លាំងជម្រើសចុងក្រោយត្រូវប្រើថ្នាំកសិកម្ម ដែលមានធាតុសកម្មដូចជា: Acetamiprid, Imidacloprid, Dinotefuran, Thiamethoxam, Fipronil ...... របៀបប្រើប្រាស់សូមមើលលើសំបកវេចខ្ចប់។

-ទ្រីបលើដំណាំស្វាយ:





ទ្រីបជាសត្វល្អិតតូចៗ មានពណ៌ត្នោតក្រមៅស្ទើរតែមើលនឹងភ្នែកមិនឃើញ វាច្រើននៅក្រោមទ្រនុងស្លឹកស្វាយខ្ចីៗ និងពេលថ្មីនេះវាមានវត្តមាននៅនឹងផ្កាស្វាយ វាបឺតជញ្ជក់ធ្វើឲ្យស្លឹកស្វាយរមួរ និងផ្កាស្វាយមានពណ៌ខ្មៅរួចរុះរោយ។ ករណីទ្រីបមានវត្តមានច្រើន គួប្រើថ្នាំកសិកម្មដែលមានធាតុ

សកម្មដូចជា:Cypermethrin, Quinalphos, Dinotefuran, Thiamethox am, Fipronil ......របៀបប្រើប្រាស់សូមមើលលើសំបកវេចខ្ចប់។

-រុយលើផ្លែស្វាយ:





បច្ចុប្បន្នពពួករុយលើផ្លែឈើ និងបន្លែហូបផ្លែត្រូវបានចាត់ទុកជាសត្វល្អិតចង្រៃចំបងមួយនៅក្នុងប្រទេសកម្ពុជាយើង ដែលសង្កេតឃើញផ្លែឈើ និងបន្លែហូបផ្លែជាច្រើនមុខរងការបំផ្លាញដូចជា: ក្រូចគ្រប់ប្រភេទ, ជំពូ, ត្របែក, ទៀប, ពុទ្រា, ស្វាយគ្រប់ប្រភេទ, ល្មុង, មៀន, ចេកគ្រប់ប្រភេទ, ល្មុត, ផ្លែទឹកដោះគោ, ត្រសក់គ្រប់ប្រភេទ, ត្រប់, ត្រឡាច, ល្ពៅ។ល។ ការបំផ្លាញនេះ យើងមិនទាន់មានវិធានការមានប្រសិទ្ធិភាពទប់ស្កាត់ និងកំចាត់នៅឡើយ ។ ជាទូទៅដង្កូវអាចរស់នៅក្នុងផ្លែឈើ និងបំផ្លាញផ្លែឈើពី៧-១៤ថ្ងៃ។

## វិធានការការពារ និងកំចាត់:

➤វិធានដាំដុះ និងអនាម័យ:

-ការបង្ការល្អបំផុត គឺរុំផ្លែឈើដោយក្រដាសកាសែតឬថង់។ ត្រូវសម្អាតប្រមូលកាកសំណល់ សំបក ស្លឹកមែកឈើ ឬផ្លែឈើដែលស្អុយជ្រុះដុតចោល ដើម្បីកាត់បន្ថយវគ្គជីវិតនៃពពួករុយមាសឬរុយក្បាលស្វា។

-យកផ្លែឈើ ដែលមានស្នាមបំផ្លាញដោយដង្កូវរុយទៅត្រាំជ្រមុជក្នុងទឹក៣-៤ថ្ងៃ ឬដាក់ក្នុងថង់ប្លាស្ទីកបិទជិតហើយដាក់ហាលថ្ងៃ បន្ទាប់មកយកផ្លែឈើនោះធ្វើជាចំណីសត្វ។

➤វិធានការគីមី

គេអាចប្រើថ្នាំកសិកម្ម ដែលមានធាតុសកម្មដូចជា: malathion, dimethoate និង fenthion ដោយបាញ់លើរុក្ខជាតិទាំងមូល និងស្លឹក ឬផ្លែឈើដែលជ្រុះជុំដើមរុក្ខជាតិរាល់សប្តាហ៍ ដោយចាប់ផ្តើម២សប្តាហ៍ មុននឹងផ្លែបានផល ហើយរហូតប្រមូលផល។ ប៉ុន្តែវិធាការនេះហាក់ដូចហួសសម័យទៅហើយ ព្រោះវាប៉ះពាល់ដល់អ្នកប្រើប្រាស់ អ្នកបរិភោគ និងបរិស្ថានធម្មជាតិ។

➤វិធានការដែលពេញនិយមនាពេលបច្ចុប្បន្ននេះ ដែលប៉ះពាល់តិចបំផុតឬស្ទើរតែមិនប៉ះពាល់ដល់អ្នកប្រើប្រាស់ អ្នក

បរិភោគ និងបរិស្ថានធម្មជាតិ គឺការប្រើប្រាស់អន្ទាក់ស្នេហ៍ពិឃាដ(PheromoneME) និង ការប្រើនុយប្រតេអ៊ីន(Protein bait)

➤ផលប្រយោជន៍នៃការប្រើប្រាស់អន្ទាក់Pheromone

-ចំណាយថវិកាតិច និងចំណេញពេលវេលា

-មានប្រសិទ្ធិភាពល្អប្រសើរក្នុងការកាត់បន្ថយដង់ស៊ីតេប្រជាករនៃពពួករុយលើដំណាំហូបផ្លែ ដោយមិនប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ អ្នកបរិភោគ

-ធានានូវគុណភាព និងរស់ជាតិផ្លែឈើ និងបន្លែហូបផ្លែ

-មិនប៉ះពាល់ដល់បរិស្ថានធម្មជាតិ(មិនសម្លាប់សត្វមានប្រយោជន៍ដែលជាសត្រូវធម្មជាតិ នៃពពួករុយចង្រៃនេះ)

-ផ្លែឈើ និងបន្លែហូបផ្លែគ្មានជាតិថ្នាំពុលធានាសុវត្ថិភាពដល់អ្នកហូបចុកនិងតម្លៃទីផ្សារក្នុងស្រុក

-អាចនាំចេញទៅក្រៅប្រទេស ប្រកួតប្រជែងលើទីផ្សារសេរីបានដោយទម្លាយរបាំងបច្ចេកទេស។

➤នុយប្រូតេអ៊ីន(Protein bait)

ការប្រើនុយប្រូតេអ៊ីនអាចទាក់ទាញប្រភេទរុយទិចផ្លែទាំងញី និង ឈ្មោល ដែលត្រូវការសារធាតុប្រូតេអ៊ីនជាអាហារសម្រាប់លូតលាស់ និង បន្តពូជពង្សរបស់។



**➤បច្ចេកទេសសម្រាប់ប្រើប្រាស់**

-ចាក់នុយប្រូតេអ៊ីនចំនួន១លីត្រជាមួយទឹកស្អាត៩លីត្រសម្រាប់ផ្ទៃដី១ហិកតា

-លាយថ្នាំពុលដែលមានក្លិនខ្សោយដូចជា:Fipronil5SC ចំនួន២០ម.លឬអូស៊ីនOshin ២០WP (Denotefuran) មួយកញ្ចប់១៦ក្រាមឬMalathion៥០EC ១០ម.ល សម្រាប់លាយជាមួយនុយប្រូតេអ៊ីន១លីត្រ។

-បាញ់នៅព្រឹកចាប់ពីម៉ោង៧:០០-៩:០០

-ចំពោះចំការឈើហូបផ្លែបាញ់ចំណុចគ្រប់ដើម

**ខ.ជម្ងឺលើដំណាំស្វាយ:**

ដំណាំស្វាយច្រើនកើតជម្ងឺ ដូចជា:

-ជម្ងឺអុចស្លឹក





ជម្ងឺនេះប្រើថ្នាំកសិកម្មការពារ និងព្យាបាល ដែលមានធាតុសកម្មដូចជា: Azoxystrobin និង Difenoconazole។

-ជម្ងឺរលួយផ្លែ(Anthracnose)





ជម្ងឺនេះប្រើថ្នាំកសិកម្មការពារ និងព្យាបាល ដែលមានធាតុសកម្មដូចជា: Azoxystrobin និង Difenoconazole។

-ជម្ងឺរលួយផ្កា



ជម្ងឺនេះប្រើថ្នាំកសិកម្មការពារ និងព្យាបាល ដែលមានធាតុសកម្មដូចជា:Difenoconazole, Propineb, Mancozeb..។

## ៦-ការប្រមូលផល

ការប្រមូលផលដើម្បីរក្សាគុណភាពផ្លែ និងមានតម្លៃខ្ពស់នៅលើទីផ្សារគឺនៅពេលផ្លែស្វាយជិតទុំ គឺងាយស្រួលក្នុងការទុកដាក់សម្រាប់ដឹកយកទៅទីឆ្ងាយៗ សម្រាប់លក់ដូរ មិនត្រូវទុកឲ្យផ្លែស្វាយទុំពេកទេ ព្រោះវារងការបំផ្លាញពីសត្វជ្រើងកណ្ដុរ រុយទិចផ្លែ និងមានជម្ងឺ ។ ត្រូវប្រើឧបករណ៍ផ្សេងៗដូចជា ឧបករណ៍ធ្វើពីដើមឫស្សីដើម្បីថ្លក់បេះផ្លែជៀសវាងការជ្រុះមកប៉ះដីផ្ទាល់ធ្វើឲ្យផ្លែជាំឬបែក។

## ឯកសារយោង

១-ដំណាំហូបផ្លែ អង្គការស៊ីដសេ-កម្ពុជា

២-សៀវភៅណែនាំអំពីការគ្រប់គ្រងសត្វល្អិត និងជម្ងឺលើដំណាំកសិកម្មភាគII Jica, ខែមករា ឆ្នាំ២០១២

៣-គេហទំព័រកសិកម្ម